**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

*****

**********

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៣៤ **នាមនាមប្រជារាស្ត្រខ្មែរ**

ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ **តុលាការកំពូល**

**សាលដីកា**

លេខ: ៦១ បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០០ ដោយ

ចុះថ្ងៃទី២៥ខែតុលាឆ្នាំ២០០០ មានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ:

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ជាប្រធាន

២- លោក ឈឹម ស៊ីផល ជាចៅក្រម

៣- លោក ជីវ កេង ជាចៅក្រម

៤- លោក ស៊ិន ឌឹម ជាចៅក្រម

៥- លោក សោម សិរីវឌ្ឍ ជាចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

លោក វ៉ាន់ បូរ៉ាត់

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ១២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៣៤ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ របស់តុលាការកំពូល ។

**<u>ចំបង:</u>** បើកបររថយន្ត ខ្វះការប្រុងប្រយ័ត្ន បណ្តាលអោយមានការគ្រោះថ្នាក់ចរាចរ ។ ប្រព្រឹត្តនៅផ្លូវជាតិលេខ៤ ឃុំរកា ស្រុកច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៨ បទល្មើសដែលមានបញ្ញត្តិអោយផ្តន្ទាទោស តាមមាត្រា៦១ និង១២៦ នៃច្បាប់ចរាចរផ្លូវគោក ដែលប្រកាសអោយប្រើតាមក្រឹត្យច្បាប់លេខ៣៨ ក.ច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ។

-ជនជាប់ចោទឈ្មោះ សុខ សារឿន ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ "ស្លាប់រំលត់បណ្តឹងអាជ្ញា" មុខរបរបើកបររថយន្ត ។

-ម្ចាស់រថយន្តឈ្មោះ វេង ចុង (ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ សាសនា

ព្រះពុទ្ធ មុខរបរលក់គ្រឿងដែក មានទីលំនៅភូមិ ពាណិជ្ជកម្ម ឃុំរកាធំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ។ ឪពុកឈ្មោះ សួរ គ្រុយ "ស" ម្តាយឈ្មោះលាង ហាក់ "រ" ប្រពន្ធឈ្មោះ ចៃ ហ្គិចគាវ មានកូន៤នាក់ ។ ទោសពីមុនគ្មាន ។ មេធាវីគ្មាន ។

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ទៀវ ស៊ីជុង ( ចុងបណ្តឹងសាទុក្ខ ) ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មានទីលំនៅកែង ផ្លូវ២១៧និង៦៧ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ផ្ទេរសិទ្ធិអោយលោក សៅ សុពល "តំណាងអោយក្រុមហ៊ុនហ្វ៉ាហ្គិនជីងត្រែនស្ពត" ។ គ្មានមេធាវី ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៩៨ របស់តំណាងក្រុមហ៊ុនភ្នំពេញហ្វូហ្គ៉ិនជីងត្រែនស្ពាត ប្តឹងម្ចាស់រថយន្តម៉ាក់ហ៊ីណូ ដែលបង្កគ្រោះថ្នាក់ដល់រថយន្ត របស់ក្រុមហ៊ុនខ្លួនបណ្តាលអោយខូចខាតយ៉ាងធ្ងន់ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៨ វេលាម៉ោង១.៣០នាទី រថយន្តក្រុមហ៊ុនខ្លួនចេញដំណើរពីភ្នំពេញ ទៅក្រុងព្រះសីហនុ ពេលទៅដល់ចំណុចហួសផ្សារកំពង់ស្ពឺប្រហែល១គីឡូម៉ែត្រ ស្រាប់តែរថយន្តម៉ាក់ហ៊ីណូ ដឹកកំទេចថ្ម ដោយល្បឿនលឿន មកបុករថយន្តក្រុមហ៊ុនខ្លួន ដែលបើកបរប្រកាប់ស្តាំនោះ បណ្តាលអោយអ្នកដំណើរជិះក្នុងរថយន្តរងរបួសជាច្រើននាក់ ហេតុនេះក្រុមហ៊ុនខ្លួនសុំអោយម្ចាស់រថយន្ត ដែលបង្កគ្រោះថ្នាក់សងថ្លៃមិនបានធ្វើអាជីវកម្ម និងខូចខាតរថយន្ត ។

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តកំពង់ស្ពឺ បានធ្វើសេចក្តីសន្និដ្ឋានថា: រថយន្តម៉ាក HINOស្នូច ពិតជាបានបើកបរខុសច្បាប់ចរាចរពិតមែន ដោយបានបុករថយន្តម៉ាកតាតា ដែលកំពុងបើកបរប្រកាន់ស្តាំ បណ្តាលអោយស្លាប់ខ្លួនឯង និងខូចខាតរថយន្តម៉ាកតាតា និងរបួសដល់អ្នកដែលជិះលើរថយន្តនោះជាច្រើនអ្នកទៀតផង ។ ហេតុនេះ សូមតុលាការសំរេចទៅតាមច្បាប់ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៥៩ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសំរេច ដូចតទៅ :

១-រំលត់បណ្តឹងអាជ្ញាលើឈ្មោះសុខ សារឿន អាយុ៣២ឆ្នាំ ភេទប្រុស របរបើកបររថយន្ត បានជាប់ចោទពីបទ បើកបររថយន្ត ខ្វះការប្រុងប្រយ័ត្ន បណ្តាលអោយបុកគ្នា និងអ្នកជិះរងរបួសរាក់ខាន ប្រកបការងារមួយរយៈ និងស្លាប់ខ្លួនឯង ប្រព្រឹត្តនៅ កំណាត់ផ្លូវជាតិលេខ៤ ត្រង់ចំណុចវិទ្យាល័យ សុខាធិល្លីក្នុងឃុំរកាធំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ កាល ពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៨ វេលាម៉ោង១១ ʰ៣០នាទី ។

២-អោយឈ្មោះ វេង ចុង ម្ចាស់រថយន្ត Hino សងប្រាក់ថ្លៃជួសជុលរថយន្ត(ម៉ាកតាតាចំនួនស្មើនិង២៥០០ $អាមេរិកទៅអោយឈ្មោះ ទាវ ស៊ីវជុង ( TE0 SIEW CHING ) តំណាងអោយក្រុមហ៊ុនភ្នំពេញ ហ្វូហ្គិនជីនត្រែនស្ពត ចាប់ពីថ្ងៃនេះ តទៅសំណើលើសពីនេះត្រូវបដិសេធចោល ។

-អោយសងប្រាក់ថ្លៃពលកម្មអោយម្ចាស់រថយន្តម៉ាកតាតា ក្នុងរយៈពេលមានគ្រោះថ្នាក់ចាប់តាំងថ្ងៃទី ១៥-៩-៩៨ រហូតដល់ថ្ងៃប្រកាសសាលក្រមនេះ គិតជាប្រាក់ក្នុង១ថ្ងៃ១០ម៉ឺនរៀល សំណើលើសពីនេះ ត្រូវបដិសេធចោល ចាប់តាំងពីថ្ងៃនេះតទៅ ។

-អោយសងប្រាក់ថ្លៃព្យាបាលអ្នករបួសដែលជិះក្នុងរថយន្តម៉ាករតាតា ដែលមានពាក្យបណ្តឹងសុំ និងលិខិត ព្យាបាលរបស់មន្ទីរពេទ្យត្រឹមត្រូវ ។ តាមមាត្រា៦១ នៃច្បាប់ចរាចរផ្លូវគោក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩១ និងមាត្រា១២៦ នៃក្រឹត្យច្បាប់លេខ៣៨ ក្រច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ។

៣-សាលក្រមនេះ ជំនុំជំរះជាសាធារណៈ ចំពោះមុខគូក្តី និងបើកផ្លូវអោយប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៩ របស់ឈ្មោះ វ៉េង ថុង ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៩៩ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ស្ពឺ ត្រង់ចំណុចទី៣ វាក្យខ័ណ្ឌទី១ ។

បានឃើញសេចក្តីសន្និដ្ឋានរបស់មហាអយ្យការ អមសាលាឧទ្ធរណ៍ថា: មិនទទួលជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៩ របស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឈ្មោះ វ៉េង ថុង ដោយបណ្តឹងហួសកំណត់ច្បាប់ ។

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារ នៃសេចក្តីសំរេច ដូចតទៅ:

១-មិនទទួលជំនុំជំរះ លើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៩ របស់ឈ្មោះ វ៉េង ថុង ។

២-សំរេចចំណាយរឿងព្រហ្មទណ្ឌលេខ១៤២ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

សាលដីកានេះ ជំនុំជំរះនិងប្រកាសជាសាធារណៈ ចំពោះមុខវ៉េង ថុង និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០០ របស់ឈ្មោះ វ៉េង ថុង ប្តឹងមិនសុខចិត្ត នឹងសាលដីកាព្រហ្មទណ្ឌលេខ២១២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល។

បានឃើញសារណាការពារ និងឆ្លើយតប ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០០ របស់លោកវ៉េង ថុង

បានឃើញសារណាការពារ និងឆ្លើយតប ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ របស់លោកទៀវ ស៊ីវជុង

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល បានសំរេចថា: បណ្តឹងឧទ្ធរណ៍របស់ឈ្មោះវ៉េង ថុង បានហួសកាលកំណត់ច្បាប់ ។ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចទៅតាមច្បាប់ ។

បានស្តាប់ចំលើយ អះអាងនាពេលសវនាការ របស់ឈ្មោះវ៉េង ថុង ( ម្ចាស់រថយន្ត ) បានឆ្លើយថា:

ខ្ញុំបាទឈ្មោះវ៉េង ថុង សូមឆ្លើយបញ្ជាក់ថា: ចំពោះគ្រោះថ្នាក់ចរាចរ ដែលបានកើតឡើង រវាងរថយន្តក្រុងម៉ាក្សតាតា របស់ក្រុមហ៊ុហ្វូវ៉ាហ្គីនធីងត្រែនស្ពត និងរថយន្តម៉ាក្សហ៊ីណូ នៅថ្ងៃទី ១៥ ខែ កញ្ញា

ឆ្នាំ១៩៩៨ នោះ គឺឈ្មោះ សុខ សារឿន ជាអ្នកជួលរថយន្តរបស់ខ្ញុំបាទ យកទៅធ្វើ អាជីវកម្មផ្ទាល់ ខ្លួន ក្នុងតម្លៃ០១ខែ២០០$ដុល្លាអាមេរិក ដោយមានកិច្ចសន្យាត្រឹមត្រូវ ដូច្នេះ រាល់ សំណងផ្សេងៗ ត្រូវ ឈ្មោះ សុខ សារឿន ជាអ្នកទទួលខុសត្រូវ ។

ការដែលតុលាការខេត្តកំពង់ស្ពឺ រំលត់បណ្តឹងអាជ្ញាលើឈ្មោះ សុខ សារឿន ហើយបង្វែរការ ទទួលខុសត្រូវលើសំណង មកលើខ្ញុំបាទនោះ ជាការពុំត្រឹមត្រូវទេ ព្រោះថ្វីត្បិតតែឈ្មោះ សុខ សារឿន បាន ស្លាប់ក៏ពិតមែន តែបងប្អូនសាច់ញាតិ របស់អ្នកស្លាប់នៅរស់ ។

ចុងក្រោយខ្ញុំបាទ សូមសំណូមពរ ដល់ក្រុមប្រឹក្សាជំនុំជំរះ មេត្តាលើកយកបណ្តឹងសាទុក្ខរបស់ខ្ញុំបាទ មកពិចារណា និងធ្វើការអង្កេតអោយបានត្រឹមត្រូវ ។ និងសូមអោយតុលាការ ពិនិត្យពិចារណាលើសំណង់ ឡើងវិញ ។

បានស្តាប់ចំលើយ អះអាងនាពេលសវនាការ របស់ឈ្មោះ សៅ សុពល បានឆ្លើយថា: ខ្ញុំបាទឈ្មោះ សៅ សុពល សូមឆ្លើយបញ្ជាក់ថា : ចំពោះគ្រោះថ្នាក់នេះ គឺបណ្តាលមកពី អ្នកបើកបររថយន្តម៉ាក្សហ៊ីណូ បើកបរ មិនគោរពច្បាប់ ដោយដឹងថា នៅពីមុខរថយន្តរបស់ខ្លួនមានឧបសគ្គនៅ តែបើកវ៉ាបំពានលើចំណែក ផ្លូវ ដែលកំពុងធ្វើដំណើរច្រាសទិសគ្នា ។ ជាហេតុធ្វើអោយមានគ្រោះថ្នាក់ កើតឡើងបណ្តាលអោយ រថយន្ត ក្រុងម៉ាក្សតាតា ខូចខាតជាទម្ងន់ និងអ្នកជិះលើរថយន្តមានភ្ញៀវជាតិ អន្តរជាតិទទួលរងរបួសជាទម្ងន់។ ចុងក្រោយ ខ្ញុំបាទសូមសំណូមពរ :

-ទាមទារថ្លៃជួសជុលរថយន្ត និងថ្លៃបង់ខាតការរកស៊ីចំនួន៩២៦៧$ (ប្រាំបួនពាន់ ពីររយហុកសិបប្រាំពីរដុល្លា) ។

-សុំអោយចេញថ្លៃព្យាបាលអ្នករបួសទាំងអស់ ។ សុំបដិសេធសាលដីកាលេខ១២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ ទាំងស្រុង ។

បានស្តាប់តំណាងមហាអយ្យការថា: ពុំមានយោបល់អ្វីបន្ថែមទៀតទេ សូមរក្សាសេចក្តីសន្និដ្ឋាននៅ ដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចំលើយដោះសារ របស់លោក វ៉េង ចុង និងចំលើយដោះសារ របស់ លោក សៅ សុពល ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០០ របស់ឈ្មោះ វ៉េង ចុង និងបណ្តឹងសាទុក្ខលេខ៣០ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ របស់ឈ្មោះ ទៀវ ស៊ីចុង ធ្វើឡើងក្នុងកំណត់

ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន ដោយយោងតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាព របស់សាលាជំរះក្តី ។

- យល់ឃើញថា លោក វេង ថុង បានប្តឹងឧទ្ធរណ៍ហួសកាលកំណត់ នៃច្បាប់ពិតមែន ដូច្នេះតាមមាត្រា៧នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី សាលាឧទ្ធរណ៍ពុំមានសមត្ថកិច្ចលើកបណ្តឹងឧទ្ធរណ៍នេះ មកជំនុំជំរះបានឡើយ ។

- យល់ឃើញថា លោក ទៀវ ស៊ីផុង ពុំបានប្តឹងឧទ្ធរណ៍ពីសាលក្រមរបស់តុលាការខេត្តកំពង់ស្ពឺទេ ធ្វើអោយសាលក្រមនេះ ចូលជាស្ថាពរ ទៅហើយ ដូច្នេះបណ្តឹងសាទុក្ខរបស់លោក ពុំអាចអោយតុលាការកំពូល ពិនិត្យឡើងវិញ លើសាលក្រមរបស់តុលាការខេត្តកំពង់ស្ពឺ បានឡើយ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ សំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី ចំពោះមុខតំណាង**

**ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

១-ទទួលបណ្តឹងសាទុក្ខលេខ១៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០០ របស់ឈ្មោះវេង ថុង និងបណ្តឹងសាទុក្ខលេខ៣០ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ របស់លោក ទៀវ ស៊ីផុង ទុកជាត្រឹមត្រូវ តាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុស នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០០ ។